ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង...
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ១៧៦៥
ថ្ងៃទី ២០-០៤-១២
បញ្ជូន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់អភិរក្សជលផលក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការរំសាយឡូត៍នេសាទក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ និងរៀបចំជាកន្លែងអភិរក្សជលផល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

### មាត្រា១..

ត្រូវបានបង្កើតជាកន្លែងអភិរក្សជលផលនៅក្នុងកន្លែងនេសាទបម្រុងនៃអតីតឡូត៍នេសាទទាំងអស់ដែលបានរំសាយក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ ដើម្បីធានាបាននូវផលស្តុកធនធានជលផល ។

### មាត្រា២..

ឈ្មោះ ទំហំ ផែនទី និងនិយាមកាកន្លែងអភិរក្សជលផលដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់អនុក្រឹត្យនេះ ។

### មាត្រា៣..

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំបោះបង្គោលសញ្ញាសម្គាល់ព្រំប្រទល់កន្លែងអភិរក្សជលផល ដោយមានកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍នេសាទពាក់ព័ន្ធ ។

### មាត្រា៤..

ការគ្រប់គ្រង ការពារ និងថែរក្សាកន្លែងអភិរក្សជលផលជាសមត្ថកិច្ចរបស់រដ្ឋបាលជលផលនិងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ។

បណ្តាសហគមន៍នេសាទ សហគមន៍មូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលមានសិទ្ធិចូលរួមសហការគ្រប់គ្រង អភិរក្ស និងការពារកន្លែងអភិរក្សជលផល ដើម្បីជួយធានានិរន្តរភាពនៃធនធានជលផល ។

### មាត្រា៥..

ត្រូវបានហាមឃាត់រាល់ការធ្វើនេសាទគ្រប់ប្រភេទនិងសកម្មភាពផ្សេងៗនៅក្នុងកន្លែងអភិរក្សជលផល លើកលែងតែការងារស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រដែលត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលជលផល ។

ការគ្រប់គ្រងកន្លែងអភិរក្សជលផលនេះ ពុំត្រូវធ្វើឱ្យរាំងស្ទះដល់ការធ្វើចរាចរណ៍ជាធម្មតាឬក្នុងករណីប្រធានសក្តិរបស់ប្រជាពលរដ្ឋឡើយ ។

### មាត្រា៦..

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់សកម្មភាពការពារកន្លែងអភិរក្សជលផលប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**មាត្រា៧.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះតាមសមត្ថកិច្ច រៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល:__**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្តពាក់ព័ន្ធ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ១៤២ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក :

-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

« ដើម្បីជូនជ្រាប »

-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោក ប្រធានមន្ទីរកសិកម្មខេត្តកណ្តាល

-លោក ប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម

-លោក ប្រធានមន្ទីរកសិកម្មខេត្តព្រៃវែង

-លោក ប្រធានមន្ទីរកសិកម្មខេត្តតាកែវ

« ដើម្បីជ្រាបនិងមុខការ »

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២

**ត.ប រដ្ឋមន្ត្រី**

**អគ្គលេខាធិការ**

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៥៣......អនក្រ.បក ចុះថ្ងៃទី...០៦.....ខែ មេសា....ឆ្នាំ២០១២

## ស្តីពីការបង្កើតកន្លែងអភិរក្សជលផលក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងខេត្តតាកែវ

១-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ៥ ខេត្តកណ្តាល ។

២-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ៦ ខេត្តកណ្តាល ។

៣-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ៩ ខេត្តកណ្តាល ។

៤-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១០ ខេត្តកណ្តាល ។

៥-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១១ ខេត្តកណ្តាល ។

៦-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០២ ខេត្តកំពង់ចាម ។

៧-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៥ ខេត្តកំពង់ចាម ។

៨-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៩ ខេត្តកំពង់ចាម ។

៩-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០១ ខេត្តព្រៃវែង ។

១០-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៤ ខេត្តព្រៃវែង ។

១១-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៥ ខេត្តព្រៃវែង ។

១២-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៦ ខេត្តព្រៃវែង ។

១៣-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៣ ខេត្តព្រៃវែង ។

១៤-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៤ ខេត្តព្រៃវែង ។

១៥-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៥ ខេត្តព្រៃវែង ។

១៦-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៨ ខេត្តព្រៃវែង ។

១៧-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ២០ ខេត្តព្រៃវែង ។

១៨-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០១ ខេត្តតាកែវ ។

១៩-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ០៥ ខេត្តតាកែវ ។

២០-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១១ ខេត្តតាកែវ ។

២១-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១២ ខេត្តតាកែវ ។

២២-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៤ ខេត្តតាកែវ ។

២៣-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៥ ខេត្តតាកែវ ។

២៤-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៦ ខេត្តតាកែវ ។

២៥-ផែនទីនិងនិយាមកាកន្លែងអភិរក្សជលផលក្នុងអតីតឡូត៍នេសាទលេខ ១៨ ខេត្តតាកែវ ។